# ព្រះវិហារបុរាណវត្តកូនសត្វ

វត្តកូនសត្វ ឬហៅតាមឈ្មោះថ្មីថាវត្តគិរីសោភា ស្ថិតក្នុងឃុំកូនសត្វ ស្រុកទឹកឈូ ខេត្តកំពត។ នៅក្នុងបរិវេណវត្ត មានសំណង់ព្រះវិហារបុរាណ សង់លើកូនទួលដែលមានស្រះទឹកព័ទ្ធជុំវិញ មានតែច្រកចូលនៅទិសខាងលិចប៉ុណ្ណោះ។ បើផ្អែកតាមសំណេរចារនៅលើហោជាងឱ្យដឹងថា ព្រះវិហារវត្តនេះកសាងឡើងក្នុងរវាងពុទ្ធសករាជ២៥០២ ត្រូវនឹងគ្រិស្តសករាជ១៩៥៩ ពោលគឺជាស្ថាបត្យកម្មបុរាណមួយទៀតក្នុងខេត្តកំពត បន្ទាប់ពីព្រះវិហារវត្តកោះផ្ដៅ ដែលស្ថិតក្នុងស្រុកកំពង់ត្រាច។[១]

ព្រះវិហារវត្តកូនសត្វ ជាសំណង់បែបបុរាណតូចច្រឡឹង រចនាលម្អប្រកបដោយក្បូរក្បាច់យ៉ាងល្អវិចិត្រ។ ព្រះវិហារនេះ ជាទម្រង់វិហារជហ្វាបួន សង់នៅលើខឿនកម្ពស់ប្រហែលជាងកន្លះម៉ែត្រ មានបង្កាន់ដៃព័ទ្ធជុំវិញ។ រចនាសម្ព័ន្ធផ្នែកខាងក្រោមព្រះវិហារគឺជាជញ្ជាំង និងឥដ្ឋបូកកំបោរបាយអ ហើយគ្រឿងបង្គុំផ្នែកខាងលើជាឈើ (រូបលេខ១)។



រូបលេខ១ ព្រះវិហារវត្តកូនសត្វមើលពីចម្ងាយ

[១] សូមអាន "វិហារបុរាណវត្តកោះផ្ដៅ" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/18834 ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះវិហារវត្តកូនសត្វជាប្រភេទវិហារជហ្វាបួន (រូបលេខ២២) មានលំនាំស្ថាបត្យកម្មដូចវិហារបុរាណតាមបណ្តាខេត្តនានា ដែលគេសង្កេតឃើញនិយមសាងសង់នៅក្នុងរវាងមួយសតវត្សមុន។[២] ស្ថិតនៅតំបន់ជុំវិញនេះគេឃើញថា ព្រះវិហារវត្តកូនសត្វ ក៏មានលក្ខណៈស្មើរប្រហាក់ប្រហែលនឹងព្រះវិហារវត្តកោះផ្តៅ (ឆ្នាំ១៩៣២) និងព្រះវិហារវត្តព្រៃតាកុយ (ឆ្នាំ១៩៣៥) ស្ថិតក្នុងខេត្តកែបដែរ (រូបលេខ២៣-២៤)។



រូបលេខ២២ ព្រះវិហារវត្តកូនសត្វ



រូបលេខ២៣ ព្រះវិហារវត្តកោះផ្តៅ



រូបលេខ២៤ព្រះវិហារវត្តព្រៃតាកុយ

(រូបថត៖ ក្រសួងវប្បធម៌, ២០២១)

ព្រះវិហារវត្តកូនសត្វ មានជណ្តើរឡើងទាំងបួនទិស ដោយនៅផ្នែកខាងមុខនិងខាងក្រោយមានជណ្តើរម្ខាងពីរ ហើយនៅផ្នែកចំហៀងទាំងសងខាងមានជណ្តើរពីរដែរ។ ព្រះវិហារនេះ គេសង់រៀបជញ្ជាំងជាប់នឹងរបៀង ពោលគឺពុំមានល្វែងបាំងសាច។ ជញ្ជាំងខាងមុខមានទ្វារចូលពីរ និងជញ្ជាំងខាងក្រោយមានទ្វារចូលពីរ រីឯនៅជញ្ជាំងចំហៀងទាំងសងខាងក៏មានទ្វារម្ខាងពីរ អមដោយបង្អួចតូចៗជុំវិញចំនួន១២។ នៅលើផ្ទៃជញ្ជាំងខាងក្រៅនៃវិហារនេះ ជាជញ្ជាំងលាតពុំមានរចនាលម្អអ្វីឡើយ (រូបលេខ២៥)។



រូបលេខ២៥ ព្រះវិហារវត្តកូនសត្វ (មើលពីពាយ័ព្យ)



រូបលេខ២៦ ព្រះវិហារវត្តកូនសត្វ (មើលពីលិច)

[២] ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដូចបានបញ្ជាក់មកខាងដើមស្រេចហើយថា ព្រះវិហារវត្តកូនសត្វជាប្រភេទវិហារបុរាណជហ្វាបួន។ ព្រះវិហារនេះ ប្រក់ក្បឿងស្រកាលេញ ហើយស្លាបដំបូលទាំងសងខាងមានជម្រាលចុះបីថ្នាក់ តែនៅត្រង់ចុងដំបូលផ្នែកកណ្ដាល គេធ្វើឱ្យហើបខ្ពស់បន្តិច (រូបលេខ៧)។ នៅលើព្រំដំបូល គេឃើញមានក្បាច់មួយជួរវត់ត្រង់ហៅថា "នាងប្រាល" ហើយនៅត្រង់ចំណុចកណ្ដាលគេលម្អដោយកំពូលម៉ិត ឬខ្លះហៅថាកំពូលព្រំ។[៣] ត្រង់កំពូលព្រំនេះ គេបំពាក់ក្បាច់រចនាពីលោហៈខ្វែងគ្នាជាបួន និងមានក្បាច់ភ្នីភ្លើងត្រង់ចុងលោហៈទាំងនោះផង (រូបលេខ៨)។ រីឯនៅត្រង់ថែងដំបូលនីមួយៗ គឺជាក្បាច់នាគដងក្ដារសណ្ដូកចុះមកដល់រងស្បូវ។ ចំពោះក្បាច់រងស្បូវនៃព្រះវិហារនេះ គេសង្កេតឃើញប្លែកគ្នាទាំងបីថ្នាក់ ពោលគឺក្បាច់រំយោល (ថ្នាក់ក្រោម) ក្បាច់ត្របកឈូក (?) (ថ្នាក់កណ្ដាល) និងរងស្បូវរចនាជារូបមនុស្សប្រណម្យ (ថ្នាក់លើបំផុត) (រូបលេខ៩)។



រូបលេខ៧ ដំបូលព្រះវិហារ មើលពីចំហៀង



រូបលេខ៨ នាងប្រាល និងកំពូលព្រំ



រូបលេខ៩ នាគដងក្ដារ និងក្បាច់រងស្បូវ

ចំពោះហោជាងទាំងពីរនៃព្រះវិហារវត្តកូនសត្វ គេសង្កេតឃើញមានក្បាច់លម្អ និងព័ត៌មានសំខាន់គួរឱ្យកត់សម្គាល់។ ហោជាងទាំងពីរនេះ គេចាក់ជាបេតុង ភ្ជាប់ទៅនឹងធ្នឹមតែម្ដង ពោលគឺពុំមែនជាហោជាងឈើ ឬរៀបឥដ្ឋឡើយ។ ក្បាច់លម្អលើហោជាងខាងកើតជាសទ្ធារបស់ តា ឈុន និង ហ៊ុន ហ៊ិន ដែលរួមប្រាក់ជាមួយគ្នាបាន១១២០រៀល។ ហោជាងនេះ ធ្វើក្នុងឆ្នាំច ដោយស្នាដៃជាងឈ្មោះ "ពិន"។ ក្បាច់លម្អលើហោជាង មានលក្ខណៈជាចង្វាយបំបែកចេញមាត់ព្រះកាល(?)។ ចុងចង្វាយក្បាច់ខាងក្រោម ផ្នែកខាងឆ្វេងមានរូបយក្សកាន់កនាគ(?) ផ្នែកខាងស្ដាំជារូបហនុមានកាន់កនាគ(?)។ រីឯចុងចង្វាយក្បាច់ផ្សេងៗ នៅផ្នែកខាងលើខ្លះជារូបផ្កាក្រពុំ ខ្លះជារូបផ្ការីកជាដើម (រូបលេខ១០)។

[៣] ហុក សុកុល ២០០៦-២០០៧: ៦៩-៧១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំណែកហោជាងខាងលិច ក៏មានលំនាំប្រហាក់ប្រហែលនឹងក្បាច់ហោជាងខាងកើតដែរ។ ហោជាងនេះ ជាសទ្ធាលោកយាយ យង (ម៉ា យង?) ក្នុងទឹកប្រាក់១១២០រៀល ហើយកសាងក្នុងឆ្នាំកុល (កុរ) ដោយស្នាដៃជាង "ឆាយ" (រូបលេខ១១)។



រូបលេខ១០ ហោជាងខាងកើត



រូបលេខ១១ ហោជាងខាងលិច

ដោយឡែក នៅផ្នែកខាងក្នុងព្រះវិហារ គេឃើញមានសសរបេតុងមូលពីរជួរអមសងខាងល្វែងគ្រឹះ ទ្រពិតានបេតុងនៅផ្នែកខាងលើ។ ពិតាននេះ គេពុំចាក់ឱ្យពេញផ្ទៃខាងលើទាំងអស់ទេ ពោលគឺគេចាក់គ្របត្រឹមតែលើល្វែងគ្រឹះតែប៉ុណ្ណោះ ដោយរក្សាទុកចន្លោះជុំវិញ ត្រង់លើរបៀង ដែលយើងអាចមើលឃើញគ្រឿងដំបូល ផ្ទោងផ្ទាន និងដែរណែងផ្នែកខាងក្រោម (រូបលេខ១២-១៤)។ ចំពោះពិតាននោះសោត ក៏ពុំមានគំនូរ ឬការលម្អអ្វីដែរ ដោយគេរក្សាទុកជាផ្ទៃលាតពណ៌ស។ រីឯផ្នែកចុងខាងលិចនៃល្វែងគ្រឹះ គឺជាបល្ល័ង្កតម្កល់ព្រះជីវ៍ ដែលគេរៀបជាបីថ្នាក់។ ប៉ុន្តែបល្ល័ង្កនេះ គេពុំរៀបជាប់នឹងផ្ទៃជញ្ជាំងខាងក្រោយ ដោយរក្សាទុកចន្លោះ (រូបលេខ១៥)។



រូបលេខ១២-១៤ ផ្នែកខាងក្នុងព្រះវិហារ និងផ្នែកខ្លះនៃរចនាសម្ព័ន្ធគ្រឿងបង្គុំខាងលើ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២១៥ ព្រះដីរ៍តម្កល់ក្នុងព្រះវិហារវត្តកូនសត្វ

នៅលើជញ្ជាំងផ្នែកខាងក្នុងព្រះវិហារវត្តកូនសត្វគេពុំឃើញមានគំនូរអំពីពុទ្ធប្រវត្តិ ឬរឿងជាតកលើជញ្ជាំងដូចវិហារផ្សេងៗឡើយ។ ផ្ទុយទៅវិញ គេឃើញមានស្លាកស្នាមសំណេរប្រយោគខ្លីៗ សរសេរនឹងធ្យូង(?) ខ្ពស់ផុតដៃ (ខ្វះសរសេរផ្តេក) មានន័យពាក់ព័ន្ធនឹងសម័យសង្គ្រាម ជាពិសេសនៅលើជញ្ជាំងខាងត្បូងដែលមានឃ្លាខ្វះដូចខាងក្រោម៖

"សូមសមមិត្តកុំសសេរលេងវិហ៊ានេះពេក ប្រយ័ត...យើងស្តី" [សូមសមមិត្តកុំសរសេរលេងវិហារនេះពេក ប្រយ័ត្ន...យើងស្តី] (រូបលេខ២១៦)។

"ជយោ! កងកម្លាំងប្រដាប់អាវុធប្រជាជន" (រូបលេខ២១៧)។

"ប្រជាជនដែលនៅតំបន់កាន់កាប់បណ្តោះអាសន្ន" (រូបលេខ២១៨)។

"សូមជូន...សមមិត្តរួមចិត្ត ស.ម បានបែកពីគ្រួសារធំទៅភូមិដ្ឋានដើមក៏សាងគ្រួសារជាសុភ័កមង្គល័ដ៏បវររបស់មិត្ត ខ្ញុំសូមជូនពរដល់អ្នកទាំងពីរបានសុភ័កមង្គល័ សេចក្តីចំរើនគ្រប់ៗគ្នា ហត្ថលេខា" [សូមជូន...សមមិត្តរួមចិត្ត សមមិត្តបានបែកពីគ្រួសារធំទៅភូមិដ្ឋានដើម កសាងគ្រួសារជាសុភមង្គលដ៏បវររបស់មិត្ត ខ្ញុំសូមជូនពរដល់អ្នកទាំងពីរបានសុភមង្គល សេចក្តីចម្រើនគ្រប់ៗគ្នា ហត្ថលេខា] (រូបលេខ២១៩)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២១៦



រូបលេខ២១៧



រូបលេខ២១៨



រូបលេខ២១៩

ដូច្នេះជារួមមក ព្រះវិហារវត្តកូនសត្វជាសំណង់បុរាណ ដែលទំនងទទួលឥទ្ធិពលលើទម្រង់សំណង់ស្ថាបត្យកម្មទូទៅពីវិហារវត្តកោះផ្ដៅ និងវិហារវត្តព្រៃតាកុយ ដែលស្ថិតនៅមិនឆ្ងាយពីគ្នា។ ចំពោះការតុបតែងក្បាច់រចនានៅលើព្រះវិហារវត្តកូនសត្វ ហាក់មានលក្ខណៈប្លែក ផ្អែកតាមគំនិតនិងចំណេះរបស់អ្នកស្រុកផ្ទាល់ ជាពិសេសក្បាច់លម្អលើព្រំដំបូល និងរង់ស្បូវ។ ដោយឡែក ចំពោះសំណេរខ្មៅៗលើជញ្ជាំងព្រះវិហារ អាចនាំឱ្យយើងនឹកឃើញតួនាទីព្រះវិហារក្នុងតំបន់ភាគនិរតី ក្នុងសម័យសង្គ្រាម ដែលធ្លាប់ធ្វើជាពេងជាង ជាបន្ទាយកងទ័ព ឬជាជង្រុកស្រូវជាដើម។ ប៉ុន្តែកង្វល់ត្រង់នេះ គេគួរមានការសិក្សា និងសាកសួរអ្នកស្រុកឱ្យបានកានតែស៊ីជម្រៅបន្ថែមទៀត។

## ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ភាគ១, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

ហុក សុកុល

២០០៦-២០០៧, "ផ្ទះប៉ិត", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២, ទំ. ៦៩-៧១, Friends of Khmer Culture, ភ្នំពេញ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត